ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសាធារណការ និងដឹកជញ្ជូន
មន្ទីរសាធារណការ និងដឹកជញ្ជូន
-ខេត្តកំពង់ធំ-
លេខ:.៧៤៥......សជណ.សក.កធ

# សេចក្តីជូនដំណឹង
## ស្តីពីកាលបរិច្ឆេទនៃការត្រួតពិនិត្យលក្ខណៈបច្ចេកទេសយានយន្ត ដោយប្រើប្រាស់ម៉ាស៊ីនត្រួតពិនិត្យលក្ខណៈបច្ចេកទេសចល័ត

**យោង**:-លិខិតលេខ ១០៨ សក.ដជគ ចុះថ្ងៃទី ៣១ ខែមីនា ឆ្នាំ២០១៧ របស់អគ្គនាយកដ្ឋានដឹក ជញ្ជូនផ្លូវគោក។

មន្ទីរសាធារណការនិងដឹកជញ្ជូនខេត្តកំពង់ធំ មានកិត្តិយសសូមជម្រាបជូនដំណឹងដល់អស់លោក លោកស្រី ជាម្ចាស់យានយន្តទាំងអស់ដែលពុំទាន់បានត្រួតពិនិត្យលក្ខណៈបច្ចេកទេសឱ្យបានជ្រាបថា៖ ដើម្បីសម្រួលដល់ប្រជាពលរដ្ឋលើការត្រួតពិនិត្យលក្ខណៈបច្ចេកទេសយានយន្ត អគ្គនាយកដ្ឋានដឹកជញ្ជូនផ្លូវគោក បានសម្រេចឱ្យក្រុមហ៊ុន CMVIC ប្រើប្រាស់ម៉ាស៊ីនត្រួតពិនិត្យលក្ខណៈបច្ចេកទេសចល័ត ដើម្បីត្រួតពិនិត្យលក្ខណៈបច្ចេកទេសយានយន្តនៅតាមបណ្តាខេត្ត ដោយម៉ាស៊ីនត្រួតពិនិត្យលក្ខណៈបច្ចេកទេសចល័តនឹងមកដល់ខេត្តកំពង់ធំតាមកម្មវិធីដូចខាងក្រោមនេះ

-លើកទី ១ ចាប់ពីថ្ងៃទី ១៨ ខែ ធ្នូ ដល់ថ្ងៃទី ២២ ខែ ធ្នូ ឆ្នាំ ២០១៧

-លើកទី ២ ចាប់ពីថ្ងៃទី ២៥ ខែ ធ្នូ ដល់ថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០១៧

ដែលមានទីតាំងនៅ ផ្លូវលេខ៤ ភូមិដំរីជាន់ខ្លា សង្កាត់ ដំរីជាន់ខ្លា ក្រុងស្ទឹងសែន ខេត្ត កំពង់ធំ(ជាប់មន្ទីរអប់រំ យុវជននិងកីឡាខេត្តកំពង់ធំ នៅតាមផ្លូវជាតិលេខ៦) ។

សេចក្តីដូចបានជម្រាបជូនខាងលើសូមអស់លោក/លោកស្រីមេត្តាត្រៀមយកយានយរបស់ខ្លួន ដើម្បីមកធ្វើការត្រួតពិនិត្យលក្ខណៈបច្ចេកទេសតាមកាលបរិច្ឆេទ និងទីតាំងដូចបានជម្រាបជូនខាងលើតាមការគួរ ។

**-សូមបញ្ជាក់**: ចំពោះម្ចាស់យានយន្តចាស់ត្រូវយកជាប់មកជាមួយនូវ វិញ្ញាបនប័ត្រត្រួតពិនិត្យ លក្ខណៈបច្ចេកទេសយានយន្តចាស់ និងCOPY ប័ណ្ណសំគាល់យានយន្ត ( កាតគ្រី )មួយសន្លឹក ។

-ចំពោះម្ចាស់យានយន្តថ្មី ត្រូវ COPY សន្លឹកពន្ធនាំចូល ០១សន្លឹក និងCOPY អត្តសញ្ញាប័ណ្ណចំនួន ០១ សន្លឹក ។

ថ្ងៃព្រហស្បតិ៍ ១៤កើត ខែមិគសិរ ឆ្នាំរកា ព.ស២៥៦១
កំពង់ធំ,ថ្ងៃទី ០១ ខែ ធ្នូ គ.ស២០១៧
**ប្រធានមន្ទីរ**

ជុំ-កុល្លា

ចម្លងជូន:
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- អគ្គនាយកដ្ឋានដឹកជញ្ជូន
- ឯកឧត្តមប្រធានក្រុមប្រឹក្សាខេត្តកំពង់ធំ
- សាលាខេត្តកំពង់ធំ
- សាលាក្រុងស្ទឹងសែន និងស្រុកទាំង ០៧
- ស្នងការដ្ឋាននគរបាលខេត្តកំពង់ធំ
- បញ្ជាការដ្ឋានកងរាជអាវុធហត្ថខេត្តកំពង់ធំ
  -ដើម្បីគោរពជូនជ្រាប-
- មន្ទីរពត៌មានខេត្តកំពង់ធំ
- ការិយាល័យសាធារណការ និងដឹកជញ្ជូនក្រុង ស្រុក
  -ដើម្បីជូនជ្រាប និងជួយផ្សព្វផ្សាយ-

-ឯកសារ-កាលប្បវត្តិ-